ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាមនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ ភ្នំពេញ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ០៣

ចុះថ្ងៃទី : ០៥-០១-០៩

សាលដីកា

លេខ : ០៧ "ខ"

ចុះថ្ងៃទី : ២៥-០១-១០

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១០ ដោយមានសមាសភាពដូចខាងក្រោម

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ០៣ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ រវាង

១. ជនជាប់ចោទឈ្មោះ [redacted] វុទ្ធា ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ កើតនៅ ភូមិត្រពាំងឈូក ឃុំកក់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ទីលំនៅមុនចាប់ខ្លួន [redacted] ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ បច្ចុប្បន្ននៅក្នុងពន្ធនាគារ ខេត្តបាត់ដំបង។

២. ជនជាប់ចោទឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើតនៅភូមិវត្តអង្គ ឃុំព្រៃឃ្មុំ ស្រុកកំពត ខេត្តកំពត ទីលំនៅមុនចាប់ខ្លួន [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨។

- <u>ត្រូវជាប់ចោទពីបទ</u> : " ឃាតកម្មគិតទុកជាមុន " ប្រព្រឹត្តនៅ ភូមិឫស្សីក្រាំង សង្កាត់សាលាក្រៅ ខណ្ឌសាលាក្រៅ ក្រុងប៉ៃលិន កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហារុន ភេទប្រុស អាយុ ៦២ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។

- តាមបណ្តឹងឧទ្ធរណ៍លេខ ១២២ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធា សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ៧៥ "ង" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូល ។

## ឯដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨ ឈ្មោះ [redacted] វុត្ថា និង ឈ្មោះ [redacted] ផល្លី បានរៀបគំរោងប្លន់យកម៉ូតូ ដោយនាំគ្នាទៅទិញកាំបិតបត់មួយនៅផ្សារក្នុងប្រទេសថៃ។ ពេលទិញកាំបិតបានហើយ ជនជាប់ចោទទាំងពីរនាក់បានហៅម៉ូតូឌុបអោយជូនទៅផ្ទះរបស់ឈ្មោះ [redacted] វុត្ថា តែពុំជួបក៏ត្រលប់មកវិញ ដល់កន្លែងកើតហេតុជាកន្លែងស្ងាត់ឈ្មោះ [redacted] វុត្ថា ធ្វើជាជ្រុះកាបូប ហើយប្រាប់អោយម៉ូតូឌុបឈប់ ខណៈដែលម៉ូតូឌុបនោះឈប់ឈ្មោះ [redacted] វុត្ថា បានហុចកាំបិតទៅឈ្មោះ [redacted] ផល្លី ៗ ក៏ចាក់ទៅលើជនរងគ្រោះជាច្រើនកាំបិត បន្ទាប់មកក៏មានការប្រតាយប្រតប់គ្នាកើតឡើង ឃើញដូចនេះឈ្មោះ [redacted] វុត្ថា រត់មកជួយក៏ត្រូវជនរងគ្រោះដណ្តើមកាំបិតបានចាក់ត្រូវមួយកាំបិតចំត្រង់ឃ្លៀក ហើយឈ្មោះនេះចាប់បានកាំបិត ក៏ហុចអោយឈ្មោះ [redacted] ផល្លី ៗ ដេញចាក់ជនរងគ្រោះរហូតដល់ស្លាប់ ក្រោយពីជនរងគ្រោះស្លាប់ ជនជាប់ចោទទាំងពីរបានយកម៉ូតូជនរងគ្រោះជិះមកមន្ទីរពេទ្យក្រុងប៉ៃលិន បន្ទាប់មកក៏ត្រូវបញ្ជូនមកមន្ទីរពេទ្យនៅខេត្តបាត់ដំបង ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបាន។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៧៥ "ង" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបងដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ

១. ផ្តន្ទាទោសឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ ២៣ឆ្នាំ និង ឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារតម្រូវអោយធ្វើការក្នុងម្នាក់ៗកំណត់ ១៦ឆ្នាំ (ដប់ប្រាំមួយឆ្នាំ ) គិតពីថ្ងៃចាប់ខ្លួន ពីថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨។

ពីបទ " ធ្វើមនុស្សឃាតគិតទុកជាមុន " ប្រព្រឹត្តនៅភូមិឬស្សីក្រាំង សង្កាត់សាលាក្រៅ ខណ្ឌសាលាក្រៅ ក្រុងប៉ៃលិន កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. បង្គាប់ឱ្យឈ្មោះ [redacted] វុត្ថា និង ឈ្មោះ [redacted] ផល្លី រួមគ្នាសងសំណងរដ្ឋប្បវេណីជាប្រាក់ចំនួន ២០ ០០០ ០០០ រ " ម្ភៃលាន " រៀល ទៅឈ្មោះ [redacted] សារុន ជាដើមបណ្តឹងរដ្ឋប្បវេណី។

៣. សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងពីរខាងលើ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុន។ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១២២ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] វុត្ថា សុំប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៥ "ង" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូល។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍

- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុជូនអង្គសវនាការ

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] វុត្ថា, [redacted] ផល្លី និង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុន បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១. មានភស្តុតាងគ្រប់គ្រាន់ចោទប្រកាន់លើឈ្មោះ [redacted] វុត្ថា និង [redacted] ផល្លី ពីបទមនុស្សឃាតគិតទុកជាមុន កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៥ "ង" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានសួរដេញដោល កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពថាពិតជាបានប្រព្រឹត្តប្រាកដមែន សូមតម្កល់សាលក្រមរបស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់អំនានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំនានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ពិនិត្យ  យល់ឃើញថា

១. បណ្តឹងឧទ្ធរណ៍លេខ ១២២ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ របស់ឈ្មោះ [redacted] វុត្ថា ជាជនជាប់ចោទធ្វើឡើងនៅក្នុងកំណត់ច្បាប់

២. ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃ ០២ ខែ ឧសភា ឆ្នាំ ២០០៨ ខ្លួន និង [redacted] ផល្លី បានហៅជនរងគ្រោះឱ្យឌុបម៉ូតូទៅផ្ទះប្អូន លុះទៅដល់ពាក់កណ្តាលផ្លូវខ្លួនធ្វើល្បិចជាជ្រុះកាបូប ហើយឱ្យម៉ូតូឈប់ រួចខ្លួនហុចកាំបិតដែលខ្លួនបានទិញត្រៀមទុកសម្រាប់ប្លន់ឱ្យទៅ [redacted] ផល្លី ។ ពេលនោះខ្លួនចុះទៅរើសកាបូប ជនជាប់ចោទ [redacted] ផល្លី ក៏ចាក់ជនរងគ្រោះចំពោះដៃផុត ជាច្រើនកាំបិតរហូតដល់ជនរងគ្រោះស្លាប់ ពួកខ្លួនក៏យកម៉ូតូជិះចេញពីកន្លែងកើតហេតុ ។

៣. មានពិរុទ្ធលើជនជាប់ចោទពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិឫស្សីក្រាំង សង្កាត់សាលាក្រៅ ក្រុងប៉ៃលិន កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨ បទល្មើសមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ៧៥ " ង " ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបងសម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២២ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ របស់ឈ្មោះ [redacted] វុត្ថា ជាជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២. តម្កល់សាលក្រមលេខ ៧៥ "ង" ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣. បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ

សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ ដើមបណ្តឹង បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 24 ខែមីនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]